# សេចក្តីថ្លែងការណ៍ព័ត៌មាន
# សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាព សិទ្ធិមនុស្សនៅប្រទេសកម្ពុជា
## សាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៤

ខ្ញុំហៀបនឹងបញ្ចប់បេសកកម្មស្វែងរកការពិតអំពីបញ្ហាសិទ្ធិមនុស្សលើកទី ១១ របស់ខ្ញុំ មកកាន់ព្រះរាជាណាចក្រកម្ពុជា ហើយជាបេសកកម្មលើកទីពីរ ចាប់តាំងពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រព្រឹត្តទៅក្នុងខែកក្កដា ឆ្នាំ២០១៣។ អ្វីដែលខ្ញុំស្នើឱ្យមានការបញ្ជាក់នោះ គឺការរកឃើញដំបូង និងការគិតអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសនេះ ចាប់តាំងពីបេសកកម្មចុងក្រោយរបស់ខ្ញុំ។ ការសន្និដ្ឋាននិងអនុសាសន៍ចុងក្រោយរបស់ខ្ញុំ នឹងមាននៅក្នុងរបាយការណ៍ដែលខ្ញុំនឹងបង្ហាញជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅក្នុងខែកញ្ញា ឆ្នាំនេះ។

ក្នុងអំឡុងពេលបំពេញបេសកកម្មនេះ ខ្ញុំបានជួបជាមួយឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម ឱម យ៉ិនទៀង ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីជាន់ខ្ពស់នៃតុលាការ អភិបាល និងអភិបាលរងខេត្តព្រះសីហនុ និងដូចជាបេសកកម្មកន្លងមករបស់ខ្ញុំដែរ ខ្ញុំបានជួបពិភាក្សាផងដែរ ជាមួយអ្នកពាក់ព័ន្ធជាច្រើនទៀតនៅកម្ពុជា រួមទាំងប្រជាពលរដ្ឋសាមញ្ញ ក្រុមយុវជន និងនិស្សិត អង្គការសង្គមស៊ីវិល មេដឹកនាំគណបក្សប្រឆាំង ក៏ដូចជា សមាជិកនៃសហគមន៍អន្តរជាតិ រួមទាំងដៃគូអភិវឌ្ឍន៍ និងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។ ខ្ញុំក៏បានទទួលប្រតិភូជាច្រើនក្រុម ដែលបានមកដាក់ញត្តិរបស់ពួកគេដល់រូបខ្ញុំ ទាក់ទងនឹងបញ្ហាសិទ្ធិដីធ្លី។

លើកនេះ ខ្ញុំអាចជួបប្រាស្រ័យទាក់ទងជាមួយអង្គការសិទ្ធិមនុស្សជាច្រើន ដែលធ្វើការងារក្នុងវិស័យផ្សេងៗ និងវាស់ស្ទង់អំពីស្ថានភាពសិទ្ធិមនុស្សទូទៅ រាប់ទាំងសិទ្ធិស្ត្រី សិទ្ធិជនពិការ សិទ្ធិស្រីស្រលាញ់ស្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ (LGBTI)។ ខ្ញុំក៏អាចធ្វើដំណើរនៅខាងក្រៅរាជធានី

ភ្នំពេញ និងមើលឲ្យឃើញផ្ទាល់ភ្នែកខ្ញុំ ពីស្ថានភាពពិតជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ច និងការបណ្តេញចេញនៅខេត្តខេត្តកោះកុង និង ខេត្តព្រះសីហនុ។

ជាបឋម ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា សម្រាប់កិច្ចសហប្រតិបត្តិការវិជ្ជមាន និងប្រកបដោយន័យស្ថាបនាដល់រូបខ្ញុំ នៅក្នុងអំឡុងពេលនៃដំណើរបេសកកម្មនេះ។ កិច្ចសន្ទនាដែលខ្ញុំមានជាមួយគូសន្ទនាពីខាងរដ្ឋាភិបាល គឺមានលក្ខណៈស្មោះត្រង់ ស្និទ្ធស្នាល និងទទួលបានព័ត៌មានច្រើន។

តាមការវាយតម្លៃជារួមរបស់ខ្ញុំ អំពីការវិវត្តលើស្ថានភាពសិទ្ធិមនុស្ស ខ្ញុំកត់សំគាល់ឃើញថា ដំណើរការរីកចំរើនក្នុងវិស័យមួយចំនួន ជាទូទៅ ស្ថិតក្នុងទិសដៅវិជ្ជមានមួយ ហើយ ខ្ញុំនៅតែជឿជាក់ថាមានហេតុផលសុទិដ្ឋិនិយមមួយសម្រាប់ការអភិវឌ្ឍរយៈពេលវែងសម្រាប់ប្រទេសជាតិ។ កិច្ចសន្យាដើម្បីដោះស្រាយភាពជាប់គាំងនយោបាយរវាងរាជរដ្ឋាភិបាល និងគណបក្សប្រឆាំង ហាក់បីដូចជាកំពុងកើតមានឡើងក្នុងគោលបំណងដើម្បីបង្កើតឲ្យមានបរិយាកាសមួយ ដែលអំណោយផលដល់ការទទួលយកអសនៈនៅក្នុងរដ្ឋសភាជាតិពីសមាជិកគណៈបក្សប្រឆាំង។ ញត្តិដ៏ច្រើនសន្ធឹកសន្ធាប់ ដែលខ្ញុំបានទទួលនៅក្នុងបេសកកម្មនីមួយៗ រាប់បញ្ចូលទាំងបេសកកម្មបច្ចុប្បន្ន បញ្ជាក់ថាមានការយល់ដឹងកាន់តែខ្លាំងឡើងក្នុងចំណោមប្រជាពលរដ្ឋអំពីសិទ្ធិមនុស្សរបស់ពួកគេ។ ពិតណាស់ របបប្រជាធិបតេយ្យ គឺសំដៅទៅលើកិច្ចសន្ទនា ការពិភាក្សាដេញដោល និង ការសម្របសម្រួលឲ្យមានការប្រកួតប្រជែងផលប្រយោជន៍សម្រាប់បុព្វហេតុប្រទេសជាតិកាន់តែខ្លាំង។ ខ្ញុំសូមស្វាគមន៍ការដោះលែង បើទោះបីជាស្ថិតក្នុងលក្ខខណ្ឌព្យួរទោសក៏ដោយ ដល់ក្រុមប្រជាពលរដ្ឋចំនួន ២៥ នាក់ ដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួនទាក់ទងនឹងព្រឹត្តការណ៍កាលពីខែ វិច្ឆិកា ឆ្នាំ ២០១៣ និងកាលពីខែមករា ឆ្នាំ២០១៤។ ទោះបីជាស្ថានភាពទូទៅនៃសិទ្ធិមនុស្ស ហាក់បីដូចជាមានស្ថេរភាពក៏ដោយ ក៏លំហរសម្រាប់សេរីភាពខាងការជួបប្រជុំដោយសន្តិវិធីនិងការបញ្ចេញមតិ ហាក់បីដូចជាបានរួមតូច នៅបន្ទាប់ពីកើតមាននូវឧប្បត្តិហេតុហិង្សាដ៏អកុសលបំផុតក្នុងសប្តាហ៍ទីមួយ ក្នុងខែមករា ឆ្នាំ២០១៤។ នៅពេលចុះទៅមើលកន្លែងបញ្ចេញមតិជាសាធារណៈ ដែលជានិមិត្តរូបនៃលទ្ធិប្រជាធិបតេយ្យ បានទៅមើលឲ្យឃើញផ្ទាល់ភ្នែកខ្ញុំ មានការសោកស្តាយណាស់ដោយឃើញថាទីនោះ ត្រូវបានហ៊ុំព័ទ្ធដោយបន្លាលួស ដើម្បីរារាំងប្រជាពលរដ្ឋមិនឲ្យចូលទៅកាន់ទីនោះ ដើម្បីអនុវត្តសេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំរបស់ពួកគេ។ វាបង្ហាញនូវចំណាប់អារម្មណ៍ថា មានការប៉ុនប៉ងដាក់លទ្ធិប្រជាធិបតេយ្យក្នុងទ្រុងមួយនៅក្នុងប្រទេសកម្ពុជា! ខ្ញុំសង្ឃឹមថា ស្ថានភាពនេះ នឹងត្រូវបានដោះស្រាយ និងថាសិទ្ធិសេរីភាពក្នុងការជួបប្រជុំដែលធានាការពារដោយរដ្ឋធម្មនុញ្ញ រាប់បញ្ចូលទាំងនៅកន្លែងបញ្ចេញមតិជាសាធារណៈ នឹងត្រូវបានធ្វើឲ្យមានដូចស្ថានភាពដើមឡើងវិញសម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

**កំណែទម្រង់ប្រព័ន្ធតុលាការ**

របាយការណ៍សំខាន់លើកទីមួយ ដែលខ្ញុំបានដាក់ជូនអង្គការសហប្រជាជាតិ បន្ទាប់ពីការចូលកាន់តំណែងរបស់ខ្ញុំជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសនេះ បានផ្តោតសំខាន់លើកំណែទម្រង់ប្រព័ន្ធតុលាការ។ ការអនុម័តច្បាប់សំខាន់ៗចំនួនបី ស្តីពីប្រព័ន្ធតុលាការ ដែលជាចំណុចស្នូលមួយនៃអនុសាសន៍របស់ខ្ញុំ។ ដូច្នេះ ខ្ញុំសូមស្វាគមន៍ជាគោលការណ៍ នូវការអនុម័តច្បាប់សំខាន់ៗទាំងបីនេះ ដោយស្ថាប័នសភាទាំងពីរ។ ច្បាប់ទាំងនេះ ពិតជាមានបញ្ញត្តិមួយចំនួន ដែលបានរៀបចំឡើង ដើម្បីពង្រឹងយន្តការស្តីពីការប្រព្រឹត្តទៅនៃប្រព័ន្ធតុលាការ ដើម្បីតុលាការអនុវត្តការងារបានឆាប់រហ័ស មានប្រសិទ្ធិភាព និងមិនលំអៀង។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមានកង្វល់អំពីបទប្បញ្ញត្តិមួយចំនួន នៅក្នុងច្បាប់ទាំងនេះ ដែលជាឧបសគ្គដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការ និង ដល់គោលការណ៍នៃការបែងចែកអំណាច។ ឧទាហរណ៍ មានបទប្បញ្ញត្តិមួយដែលមាន វត្តមានរឹងមាំ និងឥទ្ធិពលរបស់អង្គនីតិប្រតិបត្តិ នៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នមួយ ត្រូវបានប្រគល់អំណាចត្រួតពិនិត្យ និងគ្រប់គ្រងលើប្រព័ន្ធតុលាការ។ ខ្ញុំមានកង្វល់ផងដែរ ចំពោះបទប្បញ្ញត្តិមួយចំនួន ដែលបានប្រគល់អំណាចមិនសមស្របឲ្យក្រសួងយុត្តិធម៌ នូវកិច្ចការមួយចំនួនដែលទាក់ទងនឹងសកម្មភាពផ្សេងៗទៀតរបស់តុលាការ។ ចំពោះការលើកឡើងបែបនេះ ខ្ញុំយល់ឃើញថា ច្បាប់ទាំងនេះ អាចនឹងផ្តល់ក្របខណ្ឌមួយ ដើម្បីកសាងបន្ថែម និងឱកាស សម្រាប់កំណែទម្រង់បន្ថែមទៀត។ ដោដំណើរការនៃកំណែទម្រង់ប្រព័ន្ធតុលាការ គួរតែជាដំណើរការជាបន្តនៅក្នុងប្រទេសណាមួយ។ ជាធម្មតា ច្បាប់មានការវិវត្តន៍ជានិច្ច ច្បាប់អាចនិងគួរតែត្រូវបានធ្វើវិសោធនកម្មនៅពេលណាដែលមានភាពចន្លោះប្រហោង។ ខ្ញុំពិតជាសង្ឃឹមដោយស្មោះថា សមាជិកតុលាការត្រូវកាត់ផ្តាច់ចំណងទាក់ទងរបស់ខ្លួនជាមួយគណបក្សនយោបាយ ដែលមិននាំទៅរកឯករាជ្យភាពនៃតុលាការ និងទស្សនទានអំពីឯករាជ្យភាព ហើយថារដ្ឋាភិបាលនឹងផ្តល់ធនធានគ្រប់គ្រាន់បន្ថែមទៀត ដែលត្រូវការសម្រាប់យន្តការថ្មី ដែលត្រូវបានបង្កើតឡើងដោយច្បាប់ថ្មីទាំងនេះ ដើម្បីបំពេញការងារឲ្យមានប្រសិទ្ធភាព។ នៅក្នុងដំណើរការនេះ ខ្ញុំកត់សំគាល់ថា បើទោះជាបានស្នើសុំម្តងហើយម្តងទៀតពីសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងរួមទាំងពីខ្ញុំផ្ទាល់ រដ្ឋាភិបាលបានបាត់បង់ឱកាសពិគ្រោះយោបល់លើអត្ថបទច្បាប់ទាំងនេះ។ ការពិគ្រោះយោបល់បែបនេះ អាចនាំឱ្យមានភាពប្រសើរឡើងមួយចំនួន នៅក្នុងការព្រាងច្បាប់ ដែលអាចដោះស្រាយកង្វល់មួយចំនួនដែលបានលើកឡើងពីមុន។ ការខ្វះតម្លាភាព និងការចូលរួម ក្នុងការតាក់តែងច្បាប់ទាំងបីស្តីពីប្រព័ន្ធតុលាការ បង្កើតជាលំនាំមួយគួរឲ្យព្រួយបារម្ភ សម្រាប់ច្បាប់ដ៏ទៃទៀតនៅថ្ងៃអនាគត។ រដ្ឋាភិបាលបានបង្ហាញពីបំណងក្នុងការអនុម័តច្បាប់មួយចំនួន ដែលពាក់ព័ន្ធដល់ការការពារសិទ្ធិមនុស្ស ដូចជាច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីឧក្រិដ្ឋកម្ម

បច្ចេកវិជ្ជា។ អាស្រ័យហេតុនេះ ខ្ញុំលើកទឹកចិត្តយ៉ាងខ្លាំងដល់រដ្ឋាភិបាល សូមធានាឲ្យមានការផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធ ចូលរួមបង្ហាញទស្សនៈរបស់ខ្លួនលើសេចក្តីព្រាងច្បាប់នេះ។

**កំណែទម្រង់ការបោះឆ្នោត និងសភា**

ភាពជាប់គាំខាងនយោបាយដែលបង្កជាឧបសគ្គដល់ប្រទេសនេះ អស់រយៈពេលមួយឆ្នាំកន្លង នៅតែបន្តជាកង្វល់យ៉ាងខ្លាំងសម្រាប់ខ្ញុំ ពីព្រោះតែផលប៉ះពាល់របស់វាទៅលើការទទួលបានសិទ្ធិមនុស្សដោយមនុស្សគ្រប់រូបនៅកម្ពុជា។

ក្នុងចំណោមចំណុចទាំងឡាយ ក្នុងការចរចារវាងគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ ខ្ញុំកត់សំគាល់ឃើញទំនងជាមានចំណុចសំខាន់ៗចំនួនពីរដូចជា៖ (១) កិច្ចព្រមព្រៀងស្តីពីការបែងចែកអំណាចក្នុងវិស័យមួយចំនួន និង (២) កំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងដំណើរការនៃការបោះឆ្នោតទាំងមូល។ ប៉ុន្តែខ្ញុំមិនទាន់បានដឹងអំពីកិច្ចពិភាក្សាគ្នាណាមួយអំពីកំណែទម្រង់សំខាន់ៗនៃសភា។ ទាក់ទងនឹងចំណុចទីមួយ ខ្ញុំបានផ្តល់អនុសាសន៍កាលពីពេលថ្មីៗនេះថា បទបញ្ជាផ្ទៃក្នុងទូទៅរបស់សភា និងជាពិសេសរដ្ឋសភា គួរតែត្រូវបានកែតម្រូវ ដើម្បីជម្រុញឲ្យមានការបែងចែកអំណាច និងការទទួលខុសត្រូវប្រកបដោយសមធម៌ និងសមមាត្រនៅក្នុងសកម្មភាពរបស់សភា និងជាពិសេស នៅក្នុងតំណែងថ្នាក់ដឹកនាំក្នុងគណៈកម្មការសភាផ្សេងៗ។ ដូចដែលខ្ញុំបានបញ្ជាក់រួចហើយ ខ្ញុំទទួលស្គាល់ថា នៅក្នុងលទ្ធិប្រជាធិបតេយ្យ គណបក្សដែលឈ្នះឆ្នោត នឹងត្រូវគ្រប់គ្រងប្រទេស ទន្ទឹមនេះ ក៏ត្រូវយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវចំពោះទស្សនៈរបស់គណបក្សប្រឆាំងផងដែរ។ ខ្ញុំយល់ឃើញថា វាអាស្រ័យទាំងស្រុងលើគណបក្សនយោបាយទាំងពីរ ក្នុងការអនុម័តលើកិច្ចព្រមព្រៀងបែងចែកអំណាច ដែលពួកគេអាចទទួលយកបាន។

នៅត្រង់ចំណុចទីពីរ ខ្ញុំត្រូវបានលើកទឹកចិត្តដោយការទទួលយកដោយគណបក្សទាំងពីរ ទាំងគណបក្សកាន់អំណាច និងគណបក្សប្រឆាំងនូវគំនិតសនិទានភាព និងតម្រូវការសម្រាប់កំណែទម្រង់ការបោះឆ្នោត ដូចមាននៅក្នុងរបាយការណ៍របស់ខ្ញុំអំពីប្រធានបទនេះ។ ខ្ញុំស្វាគមន៍ចំពោះការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្នុងការគិតគូរពីតម្រូវការមួយចំនួនដែលមានជាយូរមកហើយឲ្យធ្វើកំណែទម្រង់។ ខ្ញុំមានសេចក្តីរីករាយ ដែលអនុសាសន៍ដែលខ្ញុំបានផ្តល់ស្តីពីកំណែទម្រង់ការបោះឆ្នោត បច្ចុប្បន្ននេះ បានក្លាយជារបៀបវារៈថ្នាក់ជាតិ រួមទាំងការផ្តល់ឋានៈធម្មនុញ្ញឯករាជ្យមួយដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយថា ការចរចានយោបាយបាននិងកំពុងបន្តធ្វើនៅក្នុងបញ្ហានេះ។ ខ្ញុំសង្ឃឹមថា គណបក្សទាំងពីរ នឹងឈានដល់ការសម្រេចមួយត្រឹមត្រូវពិតប្រាកដលើគោលការណ៍គ្រឹះ ជាជាងការគ្រាន់តែជាភាពសមស្របខាងនយោបាយដែលមានចរិត

លក្ខណៈជាភាពបណ្តោះអាសន្ននោះ។ នេះគឺជាឱកាសមួយ ក្នុងការអនុវត្តកំណែទម្រង់មួយដ៏ទូលំទូលាយ ដែលមានលក្ខណៈយូរអង្វែង ស្របតាមបទដ្ឋានអន្តរជាតិ ដើម្បីកុំឲ្យស្ថានភាពដែលបានជួបប្រទះក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកាលពីខែកក្កដា ឆ្នាំ ២០១៣ កើតមានជាថ្មីម្តងទៀត។ នូវស្ថានភាពដូចដែលមាននៅក្នុងអំឡុងពេល និងបន្ទាប់ពីពេលនៃការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រចុងក្រោយនេះ នៅខែកក្កដា ឆ្នាំ២០១៣ ទៀត។ ខ្ញុំនៅតែសង្ឃឹមថា ការពិភាក្សាអំពីការជ្រើសរើសសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) នឹងប្រព្រឹត្តទៅប្រកបដោយតម្លាភាពដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់។

នៅពេលជាមួយគ្នានេះដែរ កំណែទម្រង់ការបោះឆ្នោត មិនកំណត់ត្រឹមតែការតែងតាំងសមាជិក គជប ឬឋានៈធម្មនុញ្ញរបស់ស្ថាប័ននេះទេ។ ខ្ញុំនៅតែគាំទ្រយ៉ាងខ្លាំងដល់ការបង្កើតប្រព័ន្ធច្បាស់លាស់ថ្មីមួយនៃការចុះឈ្មោះអ្នកបោះឆ្នោត ដែលនៅតែមានសារៈសំខាន់ក្នុងការអនុវត្តសិទ្ធិក្នុងការបោះឆ្នោត។ យន្តការមួយដែលអព្យាក្រិត និងមានតម្លាភាពការដោះស្រាយបណ្តឹងទាក់ទងនឹងការបោះឆ្នោត នឹងបង្កើនទំនុកចិត្ត ក្នុងដំណើរការបោះឆ្នោតមួយកម្រិតថែមទៀត។ កំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក៏គួរតែរួមបញ្ចូលផងដែរនូវការកែប្រែ រចនាសម្ព័ន្ធ តួនាទី និងការប្រព្រឹត្តទៅរបស់ គ.ជ.ប។ ដោយឡែក តម្លៃនៃការអនុវត្តបែបនេះ អាស្រ័យទៅលើថាតើ ត្រូវធ្វើដោយរបៀបណា និងនៅពេលណា។ អាស្រ័យហេតុនេះ ខ្ញុំសូមផ្តល់ជាអនុសាសន៍ថា គ្រប់គណបក្សពាក់ព័ន្ធ គួរតែគោរពអនុវត្តតាមគម្រោងផែនការ និងពេលវេលាដែលបានកំណត់។

ទន្ទឹមនឹងការកត់សំគាល់ពីចរិតលក្ខណៈនៃការចរចារដែលកំពុងបន្តធ្វើរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង ខ្ញុំយល់ឃើញថា កំណែទម្រង់សភាឆាប់រហ័ស ដូចបានរៀបរាប់លំអិតនៅក្នុងរបាយការណ៍របស់ខ្ញុំស្តីពីកំណែទម្រង់សភា គឺមានសារៈសំខាន់ជាសារវ័ន្ត ដើម្បីឲ្យគណបក្សប្រឆាំងដើរតួនាទីប្រកបដោយអត្ថន័យ ជាគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា។ ក្នុងស្មារតីនេះ គណបក្សកាន់អំណាច គណបក្សប្រជាជន និងរដ្ឋាភិបាលផ្ទាល់ មានការទទួលខុសត្រូវធំធេងថែមទៀត ដើម្បីបង្ហាញភាពបត់បែនជាអតិប្បរមា ភាពជាអ្នកដឹកនាំ និងភាពប្រកដប្រជា និងការដោះស្រាយសំណើរកំណែទម្រង់ក្នុងការធានាដល់ការប្រព្រឹត្តទៅដោយរលូននៃលទ្ធិប្រជាធិបតេយ្យនៅក្នុប្រទេស។

គណបក្សប្រឆាំង គណបក្សសង្គ្រោះជាតិ ក៏ដូចគ្នាផងដែរ ត្រូវមានភាពសមហេតុសមផល និងភាពប្រាកដនិយមអំពីវិធីសាស្ត្ររបស់ខ្លួន ក្នុងការចរចា និងបង្កើនភាពអត់ធ្មត់ និងទំនាក់ទំនងខាងជាតិសាសន៍ដោយសុខដម្យនៅក្នុងសង្គមមួយដែលមានលក្ខណៈស្មុគស្មាញ ដូចជាសង្គមកម្ពុជា។ ខ្ញុំបានគូសបញ្ជាក់នៅក្នុង

អំឡុងពេលនៃជំនួបប្រជុំរបស់ខ្ញុំជាមួយមេដឹកនាំគណបក្សសង្គ្រោះជាតិអំពីតម្រូវការ និងអត្ថប្រយោជន៍នៃការចូលរួមរបស់ពួកគេ នៅក្នុងរដ្ឋសភា ដើម្បីភាពល្អប្រសើរឡើងថែមទៀតនៃប្រទេសនេះ។ សភាដែលដំណើរការអាចផ្តល់សំឡេងដល់ពហុភាពនៃការទាមទារនៅក្នុងសង្គម ហើយអាចដាក់អង្គនិតិប្រតិបត្តិឲ្យទទួលខុសត្រូវ គឺតំណាងឲ្យលទ្ធិប្រជាធិបតេយ្យដែលដំណើរការល្អ។ ដើម្បីឲ្យដំណើរការនេះមានទៅបាន សមាជិកសភាត្រូវតែអាចទៅជួបម្ចាស់ឆ្នោតតាមមណ្ឌលរបស់ខ្លួន និងអាចជួយលើកស្ទួយដល់ផលប្រយោជន៍របស់ពួកគេ។ ពួកគេត្រូវតែអាចបំពេញតួនាទីរបស់ខ្លួន មិនត្រឹមតែក្នុងនាមជាសមាជិកគណបក្សមួយនោះទេ ប៉ុន្តែថែមទាំងក្នុងនាមជាបុគ្គលផងដែរ ។ គណកម្មការនានារបស់សភា ត្រូវតែប្រកាន់តួនាទីរបស់ខ្លួនក្នុងការត្រួតពិនិត្យលើភាពស្របគ្នានៃច្បាប់ជាតិទៅនឹងបទដ្ឋានអន្តរជាតិ ។ ហើយពិនិត្យឲ្យបានទៀងទាត់នូវបទបញ្ញា និងការអនុវត្តរបស់រដ្ឋាភិបាល ធៀបនឹងវិសាលភាពនៃច្បាប់ដើម ដែលខ្លួនមានបំណងធ្វើឲ្យមានប្រសិទ្ធិភាព ។ លទ្ធិប្រជាធិបតេយ្យអាចដំណើរការល្អនៅកម្ពុជា ប្រសិនជាជន គ្រប់រូប គោរពបានត្រឹមត្រូវចំពោះសិទ្ធិរបស់អ្នកដទៃទៀតនៅពេលធ្វើការទាមទារ និងការអនុវត្តសិទ្ធិផ្ទាល់ខ្លួន។

## កំណែទម្រង់នៃក្រុមប្រឹក្សាធម្មនុញ្ញ

នៅពេលធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញ ក្នុងគោលដៅដាក់បញ្ចូលកំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ខ្ញុំលើកទឹកចិត្តផងដែរ ដល់គណបក្សនយោបាយនានា ប្រើប្រាស់ឱកាសនេះ ដើម្បីពិចារណាអំពីការធ្វើកំណែទម្រង់ក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីឲ្យស្ថាប័ននេះឯករាជ្យពិតប្រាកដ និងមិនប្រកាន់គណបក្សនយោបាយ ជាជាងការប្រកាន់គណបក្សទាំងអស់ ឬគណបក្សពីរ ធ្វើដូច្នោះវាអាចបង្កើនការជឿជាក់ និងការគោរពពីសំណាក់ ប្រជាជនទាំងមូល នៅក្នុងកិច្ចការដ៏មានសារៈសំខាន់សម្រាប់ប្រទេសជាតិ ដូចជាការទទួលដោះស្រាយជម្លោះបោះឆ្នោត និងការបកស្រាយរដ្ឋធម្មនុញ្ញ រួមទាំងស្ថានភាពនៃសិទ្ធិមនុស្ស នៅក្នុងស្ថាបត្យកម្មរដ្ឋធម្មនុញ្ញកម្ពុជា។

## សិទ្ធិដីធ្លី

ក្នុងអំឡុងពេលនៃដំណើរបេសកកម្មរបស់ខ្ញុំលើកនេះ ខ្ញុំមានកិច្ចប្រជុំប្រកបដោយផ្លែផ្កាជាមួយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ខ្ញុំស្វាគមន៍យ៉ាងកក់ក្តៅការរីកចម្រើនដែលបានធ្វើឡើងដោយរដ្ឋាភិបាលក្នុងការបង្កើតឡើងនូវគោលនយោបាយទាក់ទងនឹងសិទ្ធិដីធ្លី រួមទាំងការអនុម័តគោលនយោបាយលំនៅដ្ឋានជាតិ សៀវភៅសស្តីពីគោលនយោបាយដីធ្លី និងសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ កិច្ចផ្តួចផ្តើមដែលបានរង់ចាំជាយូរមកហើយនេះ បើសិនជាមានការអនុវត្តត្រឹមត្រូវ នឹងឈានទៅដោះស្រាយបណ្តឹងជាច្រើនដែលខ្ញុំបានទទួលពីបុគ្គលក្តី និងសហគមន៍ក្តី។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំនៅ

តែមានកង្វល់អំពីបញ្ហាទាក់ទងនឹងតម្លាភាព គណនេយ្យភាព និងអវត្តមាននៃយន្តការដោះស្រាយវិវាទប្រកបដោយ ប្រសិទ្ធិភាព ទាក់ទងនឹងបទបញ្ជាលេខ០០១របស់រដ្ឋាភិបាល និងកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីទូទៅ។ ខ្ញុំមានកង្វល់ជាខ្លាំងអំពីរបាយការណ៍ពីការបណ្តេញចេញដោយហិង្សាជាច្រើនដែលកើតមានក្នុងឆ្នាំ ២០១៤ ក្នុងនោះមានទាំងការបំពារបំពានលើរូបកាយ ការដុត និងបំផ្លាញផ្ទះសម្បែង ។ ពួកគេបានបង្ហាញពីតម្រូវការជាបន្ទាន់ឲ្យមាននូវគោលនយោបាយជាតិស្តីពីការតាំងទីលំនៅ ដែលកំណត់ដោយសមស្របពីដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី និងការពិនិត្យ ឡើងវិញលើរបៀបដែលរដ្ឋាភិបាលដោះស្រាយបញ្ហាទំនាស់ដីធ្លីពាក់ព័ន្ធនឹងគ្រួសារក្រីក្ររស់នៅលើដីរដ្ឋ រួមមានទាំងអ្នកដែលមិនអាចបង្ហាញនូវភស្តុតាងជាឯកសារនៃការអះអាងរបស់ពួកគេ។ មានករណីជម្លោះដីធ្លីរ៉ាំរ៉ៃជាច្រើនដែលមិនទាន់បានដោះស្រាយនៅឡើយ ក្នុងនោះរួមមានទាំងជម្លោះដីធ្លីនៅតំបន់បឹងកក់ និងបុរីកីឡា នៅរាជធានីភ្នំពេញ ស្រែអំបិល និង បុទុមសាគរ ក្នុងខេត្តកោះកុង ស្ពានឆេះ ក្នុងខេត្តព្រះសីហនុ នៅទ្រមូង ក្នុងខេត្តត្បូងឃ្មុំ នៅខ្សឹម ក្នុងខេត្តក្រចេះ នៅឡពាង ក្នុងខេត្តកំពង់ឆ្នាំង និងនៅស្ទឹងកាច់ ក្នុងខេត្តប៉ៃលិន ដែលតំណាងប្រជាពលរដ្ឋបានដាក់ញត្តិមកខ្ញុំ ក្នុងអំឡុងពេលនៃដំណើរបេសកកម្មលើកនេះ។

ខ្ញុំសូមស្វាគមន៍ចំពោះដំណឹងថា ការផ្អាកផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងបន្តអនុវត្ត។ ការផ្អាកនេះគួរតែនៅជាធរមាន រហូតដល់មានគោលនយោបាយមួយរឹងមាំត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយផលប៉ះពាល់នៃសម្បទានទាំងនេះ ទៅលើសិទ្ធិប្រជាពលរដ្ឋ។ នៅក្នុងកិច្ចជួបពិភាក្សាគ្នាមួយចំនួនដែលខ្ញុំមានជាមួយសហគមន៍ដែលរងផលប៉ះពាល់ដោយសិទ្ធិដីធ្លី នាំឲ្យខ្ញុំយល់ឃើញថា ការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច មិនត្រូវបានគ្រប់គ្រងបានល្អទេនៅក្នុងប្រទេសនេះ ដែលជាលទ្ធផលធ្វើឲ្យប្រជាជនសាមញ្ញជាច្រើនជំនាន់ទៅមុខទៀតរងការឈឺចាប់ដ៏មិនគួរចាំបាច់នេះ។ សូម្បីតែមេដឹកនាំជំនាន់បច្ចុប្បន្ននេះនឹងត្រូវបន្តធ្វើដំណើរឆ្ពោះទៅមុខ ក៏ផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដ៏ទៃ នៅតែស្ថិតនៅជាមួយដ៏គួរជូចត់ផងដែរ។ ខ្ញុំមិនទាន់បានឃើញមានការសិក្សាណាមួយ មានលក្ខណៈទូលំទូលាយ និងដែលអាចជឿទុកចិត្តបាន ដែលបង្ហាញថា ប្រជាជននៃប្រទេសនេះ បានទទួលចំណែក ភាគផលពីសម្បទានដីសេដ្ឋកិច្ចទេ។ របួស និងសោកនាដកម្មដែលប្រជាជនបានទទួលរងផលប៉ះពាល់ដោយ សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត និងការរំលោភយកដីធ្លី និងការតស៊ូស្វិតស្វាញរបស់ប្រជាពលរដ្ឋដើម្បីទាមទារយុត្តិធម៌ នឹងត្រូវបានលើកមកនិយាយហើយនិងនិយាយម្តងហើយម្តងទៀត។ ការដឹងលឺពីភាពអយុត្តិធម៌ នឹងតែបន្តនិយាយទៅដល់មនុស្សជំនាន់ថ្មីក្នុងរយៈពេលដ៏យូរទៅមុខទៀត បើមិនមានការដោះស្រាយបានត្រឹមត្រូវនោះទេមិនត្រឹមតែចំពោះករណីថ្មី ប៉ុន្តែចំពោះករណីនានាដែលប្រជាពលរដ្ឋរងការឈឺចាប់ដោយសារការបណ្តេញចេញជាយូរមកហើយនោះ ។

## សិទ្ធិការងារ

ក្នុងបេសកកម្មនេះ ខ្ញុំបានជួបប្រាស្រ័យជាមួយអ្នកពាក់ព័ន្ធជាច្រើនដែលធ្វើការក្នុងវិស័យទំនាក់ទំនង ខាង ឧស្សាហកម្ម ដែលជាប្រភពនៃការខ្វែងយោបល់គ្នា ប្រឈមមុខដាក់គ្នា និង អំពើហិង្សាក្នុងអំឡុងពេលកន្លង មកថ្មីៗនេះ។ ការជួបប្រជុំរបស់ខ្ញុំជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ តំណាងសហជីព អ្នកបញ្ញាទិញ ក៏ដូចជាតំណាងអ្នកគ្រប់គ្រង/ម្ចាស់រោងចក្រ ដូចជាសមាគមកាត់ដេរ GMAC និង CAMFEBA ទទួលបាន លទ្ធផលល្អ។ ខ្ញុំមានការរីករាយដោយកត់សំគាល់ឃើញថា ការព្រមព្រៀងគ្នាមានការលេចធ្លោក្នុង ចំណោមតួអង្គ សំខាន់ៗទាំងអស់ក្នុងវិស័យនេះអំពីលក្ខណៈវិនិច្ឆ័យដែលអនុវត្តដើម្បីកំណត់ ប្រាក់ឈ្នួលអប្បបរមា។ ក្នុងឋានៈ ជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ រដ្ឋាភិបាលកម្ពុជាត្រូវតែធ្វើការដើម្បី ធានាថា ប្រាក់ឈ្នួលអប្បបរមាកម្រិតជាតិត្រូវបានកំណត់ក្នុងកម្រិតមួយដែលគ្រប់គ្រាន់ដើម្បីផ្តល់ឲ្យកម្មករ កម្មការិនី និង ក្រុមគ្រួសាររបស់គេ រស់នៅបានសមរម្យ។

នៅក្នុងការជួបប្រាស្រ័យរបស់ខ្ញុំជាមួយអ្នកពាក់ព័ន្ធជាច្រើនអំពីបញ្ហាការងារ ខ្ញុំមានការព្រួយបារម្ភដែល បានដឹងថា កម្មករ កម្មការិនី និង មេសហជីពមួយចំនួន បានប្រឈមមុខនឹងការគម្រាមកំហែង និង អំពើបំភិត បំភ័យ ដោយសារពួកគេចូលរួមក្នុងសកម្មភាពឧស្សាហកម្ម។ ចំពោះចំណុចនេះ ខ្ញុំមានការភ្ញាក់ផ្អើលពីការកើន ឡើងយ៉ាងខ្លាំងនៃការបំភិតបំភ័យពីស្ថាប័នតុលាការទៅលើសកម្មជនសហជីពនៅក្នុងខែមេសា និង ឧសភា ដែលរួមមានទាំងការចាប់ខ្លួននៅក្នុងខេត្តកណ្តាល កំពង់ស្ពឺ និង តាកែវ ព្រមទាំងការបង់ប្រាក់ធានានៅក្រៅឃុំ បណ្តោះអាសន្នដែលមិនធ្លាប់មានពីមុនមក ចំនួន ២៥០០០ ដុល្លារ ក្នុងរឿងក្តីប្រឆាំង អាត់ ធន់ ប្រធានសហជីព ឯករាជ្យធំជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានចោទប្រកាន់ពីបទញុះញង់។ លើសពីនេះ ខណៈពេលដែលខ្ញុំមានការរីករាយដោយមើលឃើញការដោះលែងអ្នកទាំង ២៥ នាក់ ដែលបានចាប់ខ្លួន និង កាត់ទោសពីបទជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅថ្ងៃទី ២៣ ខែវិច្ឆិកា និង នៅថ្ងៃទី ២ និង ៣ ខែ មករានោះ ខ្ញុំមានក្តីបារម្ភពីការផ្តន្ទាទោសទៅលើអ្នកទាំងនេះដោយគ្មានភស្តុតាងជឿជាក់គ្រប់គ្រាន់ បន្ទាប់ពី សវនាការកាត់ទោសដែលពុំបានឆ្លើយតបទៅនឹងបទដ្ឋានជម្រះក្តីដោយយុត្តិធម៌ជាអន្តរជាតិ ហើយក្នុងរឿងក្តី ភាគច្រើន សវនាការកាត់ទោសធ្វើឡើងទៅលើអ្នកដែលពុំបានធ្វើអ្វី ក្រៅពីអនុវត្តសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ គេក្នុងការបញ្ចេញមតិ និង ការជួបប្រជុំ។ ខ្ញុំសូមអំពាវនាវឲ្យរដ្ឋាភិបាល និង អ្នកពាក់ព័ន្ធផ្សេងទៀតចាត់វិធានការ ចាំបាច់ទាំងអស់ដើម្បីធានាថា សិទ្ធិខាងសហជីពរបស់កម្មករ កម្មការិនីទាំងអស់ក្នុងប្រទេសកម្ពុជា ត្រូវបានគោរពយ៉ាងពេញលេញ និង សកម្មជនសហជីពអាចបំពេញសកម្មភាពរបស់គេក្នុងបរិយាកាសមួយ ដែលគ្មានការបំភិតបំភ័យ និង ហានិភ័យចំពោះសន្តិសុខ ឬ ជីវិតផ្ទាល់ខ្លួនរបស់គេឡើយ។ ចំពោះចំណុចនេះ

ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាល ដើម្បីធានាថា ច្បាប់ណាមួយស្តីពីសហជីព ដែលត្រូវអនុម័តនោះ លើកកម្ពស់សិទ្ធិសេរីភាពផ្នែកសមាគមរបស់កម្មករ កម្មការិនី ជាជាងរឹតត្បិតលើពួកគេ។ ខ្ញុំមានសេចក្តីរីករាយដោយសារឯកឧត្តមរដ្ឋមន្ត្រី អ៊ិត សំហេង ធានាចំពោះខ្ញុំថា ច្បាប់នេះនឹងអនុលោមពេញលេញ ទៅនឹងអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ (ILO) និង រដ្ឋធម្មនុញ្ញកម្ពុជា។ ប៉ុន្តែ ចាំបាច់ត្រូវមានការពិនិត្យសើរើឡើងវិញចំពោះសេចក្តីព្រាងច្បាប់បច្ចុប្បន្ន ដើម្បីធានាពីការអនុលោមនេះ។

**លំហលិទ្ធិប្រជាធិបតេយ្យ**

ដូចបានបញ្ជាក់ជូនខាងលើ លំហលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជាបានរួមតូចក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ រួមទាំងក្នុងអំឡុងពេលចាប់តាំងពីដំណើរទស្សនកិច្ចរបស់ខ្ញុំលើកមុននៅក្នុងខែមករា ឆ្នាំនេះ។ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់ខ្ញុំ ខ្ញុំបានឆ្លៀតឱកាសទៅមើលទីលានប្រជាធិបតេយ្យ ហើយខ្ញុំមានការភ្ញាក់ផ្អើលដោយឃើញថា ទីលាននេះត្រូវបានហ៊ុំព័ទ្ធដោយបន្លារលួស និង របាំងដែកយ៉ាងពេញទំហឹង។ការយកទីលានប្រជាធិបតេយ្យធ្វើជាទីតាំងយោធា ពុំមានមូលហេតុផ្លូវច្បាប់ ហើយវាមានផលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសេរីភាពជាមូលដ្ឋានក្នុងការបញ្ចេញមតិ និង ជួបជុំរបស់ប្រជាជនកម្ពុជាទាំងអស់។ នៅពេលបញ្ចប់ដំណើរទស្សនកិច្ចរបស់ខ្ញុំ ខ្ញុំនៅតែមានភាពមិនច្បាស់លាស់អំពីអត្ថិភាព ឬ បញ្ហាផ្សេងទៀតពីបម្រាមហាមមិនឲ្យធ្វើបាតុកម្ម និង សូមអំពាវនាវឲ្យរដ្ឋាភិបាល ធ្វើការបញ្ជាក់ជាសាធារណៈថា បម្រាមដែលរដ្ឋាភិបាលប្រកាសកាលពីដើមខែមករា ដែលពុំមានមូលហេតុផ្លូវច្បាប់តាំងពីដំបូងនោះ ពុំអនុវត្តបន្តទៀតឡើយ។ លើសពីនេះ ខ្ញុំសូមអំពាវនាវឲ្យរដ្ឋាភិបាលផ្សព្វផ្សាយពីលទ្ធផលនៃការស៊ើបអង្កេតលើព្រឹត្តិការណ៍ហិង្សាដែលបានកើតឡើងនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៣ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ និង នៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១៤ ដែលបណ្តាលឲ្យស្លាប់មនុស្សប្រាំពីរនាក់ របួសជាច្រើន និង បាត់ខ្លួនកុមារអាយុ ១៦ ឆ្នាំ ឈ្មោះ ខឹម សម្បត្តិ។ ចំពោះចំណុចចុងក្រោយនេះ ខ្ញុំសូមអំពាវនាវឲ្យរដ្ឋាភិបាលបញ្ជាក់ពីវិធានការស៊ើបអង្កេតលើការបាត់ខ្លួនកុមារនេះ ដែលមានគេឃើញចុងក្រោយថាមានហូរឈាមដោយសារត្រូវរបួសដោយគ្រាប់កាំភ្លើងពីគ្រាប់ចំទ្រូងនៅលើផ្លូវវេងស្រេងនៅថ្ងៃទី ៣ ខែ មករា។

ក្រៅពីនេះ ខ្ញុំមានការព្រួយបារម្ភចំពោះ ផែនការតាក់តែងច្បាប់ដែលគម្រាមកំហែងរឹតត្បិតលំហប្រជាធិបតេយ្យថែមទៀតក្នុងប្រទេសកម្ពុជា។ ក្នុងដំណើរទស្សនកិច្ចរបស់ខ្ញុំ តំណាងសង្គមស៊ីវិលបានបញ្ជាក់ពីក្តីកង្វល់របស់គេទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធ័រណិត និង សេចក្តីព្រាងច្បាប់ស្តីពីសមាគម និង អង្គការក្រៅរដ្ឋាភិបាល។ ខណៈពេលច្បាប់ណាមួយកំណត់ពីសេរីភាពបញ្ចេញមតិតាមប្រព័ន្ធអេឡិចត្រូនិច ព្រមទាំងការបង្កើត និង ដំណើរការទៅលើសមាគម និង អង្គការក្រៅរដ្ឋាភិបាល ពិតជាមានក្តីកង្វល់

សម្រាប់សង្គមស៊ីវិលហើយនោះ ក្តីកង្វល់ទាំងនេះត្រូវបានកាន់តែធ្វើឲ្យធ្ងន់ធ្ងរដោយសារការខកខានរបស់រដ្ឋាភិបាលក្នុងការផ្តល់ព័ត៌មានអំពីស្ថានភាពរបស់សេចក្តីព្រាងច្បាប់ទាំងនេះ ព្រមទាំងពីពេលវេលាសង្ឃឹមទុកសម្រាប់អនុម័តចេញជាច្បាប់។ ភាពលាក់លៀមក្នុងសង្គមដែលប្រេះឆា បណ្តាលនូវមន្ទិលសង្ស័យ។ ខ្ញុំបានឆ្លៀតឱកាសពិភាក្សាជាមួយរដ្ឋាភិបាលលើពង្រាងច្បាប់ទាំងពីរ ។ ខ្ញុំសូមបញ្ជាក់ថា សិទ្ធិរបស់សាធារណជន រួមមានសមាជិកនៃសង្គមស៊ីវិល មានសិទ្ធិចូលរួមក្នុងដំណើរការតាក់តែងច្បាប់ ។

## ស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យ

វិធីសាស្រ្តដែលខ្ញុំបានធ្វើឡើងចំពោះការបំពេញអាណត្តិរបស់ខ្ញុំ ធ្វើឡើងដើម្បីវាយតម្លៃជាបឋមពីប្រសិទ្ធភាពរបស់ស្ថាប័នរដ្ឋក្នុងការលើកកម្ពស់ និង ការពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។ ស្ថាប័នតុលាការជាចំណុចផ្តោតនៃរបាយការណ៍សំខាន់បឋមរបស់ខ្ញុំ។ នៅក្នុងលទ្ធិប្រជាធិបតេយ្យដែលមានដំណើរការល្អ ប្រសិនបើមានប្រជាពលរដ្ឋមានទុក្ខព្រួយពួកគេនឹងយកបញ្ហានេះទៅតុលាការ។ ប៉ុន្តែ ដោយផ្អែកលើព័ត៌មានដែលខ្ញុំបានទទួល ស្ថាប័នតុលាការហាក់ដូចជាមិនមានការគោរព ឬ មានការជឿជាក់ពីប្រជាជនជាច្រើន។ សម្រាប់ប្រជាជនសាមញ្ញភាគច្រើន ថ្លៃទទួលបានសេវាពីតុលាការក៏មានតម្លៃខ្ពស់។ ក្រុមរងគ្រោះភាគច្រើន ក៏បានប្រាប់ខ្ញុំផងដែរពីការដែលពួកគេទទួលការរើសអើងពីស្ថាប័នដែលគួរតែការពារ និង គោរពសិទ្ធិរបស់គេ។ បន្ទាប់ពីពិនិត្យ លើស្ថាប័នតុលាការ ខ្ញុំឃើញនូវប្រសិទ្ធភាព និង លទ្ធភាពរបស់សភា ក្នុងការតំណាងមណ្ឌលរបស់ខ្លួន។ ការរកឃើញរបស់ខ្ញុំបង្ហាញថា មានទំនាក់ទំនងផ្ទាល់បន្តិចបន្តួចរវាងសមាជិកសភា និង ប្រជាពលរដ្ឋ។ នៅក្នុងលទ្ធិប្រជាធិបតេយ្យដែលមានដំណើរការល្អ ប្រជាពលរដ្ឋទៅរកតុលាការ ឬ ទៅសមាជិកសភា ដើម្បីបង្ហាញពីទុក្ខព្រួយរបស់ខ្លួន និងសុំឲ្យជួយ។ ប៉ុន្តែ ក្នុងប្រទេសកម្ពុជា សមាជិកសភាមិនអាចធ្វើឲ្យអំណាចនីតិប្រតិបត្តិមានការទទួលខុសត្រូវបាន ដូច្នេះសមាជិកសភាមិនអាចតំណាងផលប្រយោជន៍មណ្ឌលរបស់ខ្លួនដោយមានអត្ថន័យ។ អាស្រ័យហេតុនេះ ខ្ញុំគោរពតាមរបាយការណ៍ស្តីពីកំណែទម្រង់សភា ដែលក្នុងនោះមាននិយាយពីកំណែទម្រង់ការបោះឆ្នោត។ ក្នុងរបាយការណ៍នីមួយៗនៃរបាយការណ៍ទាំងនេះ ខ្ញុំបានបង្ហាញពីភាពខ្វះចន្លោះដែលមាន និងផ្តល់នូវអនុសាសន៍សម្រាប់កំណែទម្រង់ស្ថាប័នទាំងនេះ។

នៅគ្រប់ដំណើរបេសកកម្មរបស់ខ្ញុំ ខ្ញុំបានដឹងថា ការខកខានរបស់ស្ថាប័នរដ្ឋក្នុងការគោរពសិទ្ធិរបស់ពលរដ្ឋ គឺជាមូលហេតុដែលប្រជាពលរដ្ឋសាមញ្ញមករកខ្ញុំ ដោយសារការអស់សង្ឃឹមក្នុងការបង្ហាញពីស្ថានភាពលំបាករបស់គេ និង បានដាក់ញត្តិមកឲ្យខ្ញុំជួយ។ នេះគឺជាមូលហេតុផងដែរដែលប្រជាពលរដ្ឋជួបជុំគ្នា និងដាក់ញត្តិដោយផ្ទាល់ទៅគេហដ្ឋានរបស់នាយករដ្ឋមន្ត្រី អង្គការសហប្រជាជាតិ និង ស្ថានទូត និងជាមូលហេតុដែលពួកគេដើរតាមដងផ្លូវដើម្បីសំដែងពីទុក្ខព្រួយរបស់គេ។

នៅក្នុងបរិបទនេះ ខ្ញុំបានយល់ឃើញថាវាដល់ពេលក្នុងការពិនិត្យមើលពីតម្រូវការ ឬ ភាពពេញចិត្តនៃការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យក្នុងប្រទេសកម្ពុជា។ ខ្ញុំបានស្វែងរកជាមួយអ្នកពាក់ព័ន្ធជាច្រើនក្នុងពេលបេសកកម្មរបស់ខ្ញុំកាលពីដើមឆ្នាំនេះ ក៏ដូចជាបេសកកម្មបច្ចុប្បន្ន នូវលទ្ធភាពបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យ ដែលអាចពង្រីកវិសាលភាពសិទ្ធិ ធ្វើជាស្ថាប័នចម្បងដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ធ្វើអនុសាសន៍ស្តីពីគោលនយោបាយទៅរដ្ឋាភិបាល ព្រមទាំងការពារសិទ្ធិពលរដ្ឋ ដោយមានសិទ្ធិអំណាចស៊ើបអង្កេតរឿងក្តីរំលោភសិទ្ធិមនុស្ស។ ខណៈពេលដែលហាក់ដូចជាមានការព្រមព្រៀងទូលំទូលាយស្តីពីតម្រូវការសម្រាប់យន្តការបែបនេះក្នុងប្រទេសនេះ ក្តីកង្វល់ត្រូវបានបង្ហាញក្នុងលក្ខណៈផ្សេងៗគ្នា ថាតើក្នុងស្ថានភាពនយោបាយបច្ចុប្បន្ននេះ អាចបង្កើតគណៈកម្មការសិទ្ធិមនុស្សជាតិឯករាជ្យ និងឬ តែងតាំងមនុស្សឯករាជ្យពិតប្រាកដដែលមានគុណសម្បត្តិគ្រប់គ្រាន់ធ្វើជាសមាជិកគណៈកម្មការបានដែរឬទេ។ ប្រជាពលរដ្ឋបានប្រាប់ខ្ញុំថា ់យើងមិនអាចទៅតុលាការ សភា ឬ នីតិប្រតិបត្តិបានទេ៉។ នេះជាទស្សនៈដែលសំដែងឡើងដោយដៃគូសន្ទនាជាច្រើនរបស់ខ្ញុំ។ របៀបដែលសេចក្តីព្រាងច្បាប់មួយចំនួនប្រញាប់បញ្ជូនទៅសភាដោយគ្មានការពិភាក្សា ឬ ពិគ្រោះយោបល់ពិតប្រាកដ បានបន្ថែមនូវការសង្ស័យដល់តំណាងសង្គមស៊ីវិលមួយចំនួន។

នៅពេលពិចារណាត្រឹមត្រូវពីទស្សនៈបែបនេះ ខ្ញុំយល់ឃើញថា ប្រសិនបើភាគីទាំងអស់ប្តេជ្ញាធ្វើឲ្យជោគជ័យ ការងារអាចចាប់ផ្តើមសម្រាប់ការឆ្ពោះទៅបង្កើតស្ថាប័ននេះ។ ក្នុងប្រទេសជាច្រើនដែលមានស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យពេញសិទ្ធិ លក្ខខណ្ឌសម្រាប់ការបង្កើតដំបូងមិនមែនសុទ្ធតែល្អពីដំបូងនោះទេ ប៉ុន្តែគេបានមើលឃើញពីការរីកចម្រើនក្នុងពេលត្រឹមត្រូវ។ ដោយពិចារណាទៅលើកេរ្តិ៍ដំណែលនៃអតីតកាលប្រកបដោយសោកនាដកម្ម ជាពិសេសផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច ទៅលើអ្នកក្រីក្រ និង សហមន៍ជនជាតិដើមភាគតិច ព្រមទាំងការប្រឈមផ្នែកសិទ្ធិមនុស្សដែលប្រទេសនេះកំពុងជួបប្រទះ ខ្ញុំមានជំនឿពីតម្រូវការនូវគណៈកម្មការសិទ្ធិមនុស្សជាតិឯករាជ្យពិតប្រាកដក្នុងប្រទេសកម្ពុជា។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា វានឹងនាំមកនូវតម្លៃបន្ថែមចំពោះហេដ្ឋារចនាសម្ព័ន្ធសិទ្ធិមនុស្សសព្វថ្ងៃ តែក្នុងករណីដែលឯករាជ្យភាពរបស់វាត្រូវបានធានាទាំងក្នុងច្បាប់ និង ទាំងក្នុងការអនុវត្តជាក់ស្តែង ដោយអនុលោមយ៉ាងពេញលេញទៅនឹងគោលការណ៍ទីក្រុងប៉ារីស។

### ស្ថានភាពពលករទេសន្តរប្រវេសន៍មកពីប្រទេសថៃ

ការវិលត្រឡប់របស់ពលករទេសន្តរប្រវេសន៍កម្ពុជា និង គ្រួសាររបស់គេជាង ២២៥០០០ នាក់មកពីប្រទេសថៃ ក្នុងនោះរួមមានស្ត្រីជាង៧៤០០០ នាក់ និង កុមារជាង ១៥០០០ នាក់ ក្នុងអំឡុងពេលមិនដល់ពីរសប្តាហ៍ ហើយរបាយការណ៍ពីការស្លាប់ជាច្រើននៅក្នុងដំណើរការនេះ គឺជាបញ្ហាកង្វល់សិទ្ធិមនុស្ស។ ខ្ញុំបានពិភាក្សាបញ្ហានេះជាច្រើនដងអំឡុងពេលបេសកកម្មរបស់ខ្ញុំ ក្នុងកិច្ចប្រជុំជាមួយរាជរដ្ឋាភិបាលកម្ពុជា និង

អ្នកផ្សេងៗទៀត។ ខ្ញុំសូមសរសើរពីកិច្ចខិតខំប្រឹងប្រែងភ្លាមៗរបស់រដ្ឋាភិបាលកម្ពុជា ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ក្នុងការដឹកជញ្ជូនពលករពីព្រំដែនទៅសហគមន៍របស់គេ និងជួយពួកគេក្នុងដំណើរការសមាហរណកម្ម ជាពិសេស ដោយពិចារណាពីការទទួលស្គាល់ការប្រឈមជាច្រើនដែលបណ្តាលមកពីការវិលត្រឡប់ភ្លាមៗ និង ច្រើនសន្ធឹកសន្ធាប់។ ទោះបីអាណត្តិរបស់ខ្ញុំត្រូវពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាក៏ដោយ ខ្ញុំបានទទួលពីរដ្ឋាភិបាលថៃនូវព័ត៌មានស្តីពីជំហររបស់គេលើបញ្ហានេះ។ ខ្ញុំយល់ឃើញថា រដ្ឋាភិបាលថៃគួរស៊ើបអង្កេតការស្លាប់របស់ប្រជាជនកម្ពុជានៅប្រទេសថៃ និង បង្ហាញពីមូលហេតុស្ថិតនៅក្រោយការបញ្ជូនត្រឡប់ភ្លាមៗ និង ច្រើនសន្ធឹកសន្ធាប់របស់ពលរដ្ឋកម្ពុជា។ ខ្ញុំឆ្លៀតឱកាសនេះសូមអំពាវនាវរដ្ឋាភិបាលថៃឲ្យស៊ើបអង្កេតការស្លាប់របស់អ្នកកាប់ឈើជនជាតិកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដែលជាការព្រួយបារម្ភរបស់ខ្ញុំ។

ដោយសារប្រាក់ផ្ញើមកពីពលករទេសន្តរប្រវេសន៍ ជាប្រភពចំណូលសំខាន់សម្រាប់សហគមន៍ជនបទភាគច្រើនក្នុងប្រទេសកម្ពុជា ខ្ញុំមានការរីករាយដែលថា រដ្ឋាភិបាលទាំងពីរមានឆន្ទៈសម្របសម្រួលតាមផ្លូវច្បាប់ចំពោះការវិលត្រឡប់ទៅប្រទេសថៃវិញចំពោះពលករទេសន្តរប្រវេសន៍ណាដែលចង់ទៅវិញ ក្នុងរបៀបមួយដែលបង្កើនការការពារប្រឆាំងនឹងការជួញដូរ និង ការរំលោភសិទ្ធិមនុស្សផ្សេងទៀត។ កិច្ចខិតខំរបស់រដ្ឋាភិបាលកម្ពុជាក្នុងការសម្របសម្រួលនូវនិយតកម្មនៃស្ថានភាពផ្លូវច្បាប់របស់ពលករដែលទៅបរទេស រួមទាំងការកាត់បន្ថយចំណាយក្នុងការទទួលបានលិខិតឆ្លងដែនថ្មី និង សម្របសម្រប់ការចេញលិខិតឆ្លងដែននេះ គឺជារឿងគួរឲ្យសរសើរ។

## សេចក្តីសន្និដ្ឋាន

ខ្ញុំសូមបញ្ជាក់ឡើងវិញពីការយល់ឃើញរបស់ខ្ញុំថា កំណែទម្រង់ពិតប្រាកដក្នុងដំណើរនៃអភិបាលកិច្ចគឺជារឿងជៀសមិនផុតក្នុងប្រទេសកម្ពុជា។ ប៉ុន្តែហាក់ដូចជានៅមានការស្ទាក់ស្ទើរខ្លះ ហើយមានការខ្វះឆន្ទៈស្មោះត្រង់ក្នុងការទទួលស្គាល់ចំពោះសារដែលបានសំដែងយ៉ាងលឺខ្លាំងៗ និងច្បាស់លាស់របស់ប្រជាពលរដ្ឋ។ សិល្បៈនៃការគ្រប់គ្រងគឺជាសិល្បៈនៃការចាត់ចែងការផ្លាស់ប្តូរ។ វានិយាយពីការបង្ហាញពីភាពជាបុរសរដ្ឋ និង អាចយកអ្នកផ្សេងដើរតាមជាមួយផង។ អ្នកដែលទប់ទល់ការផ្លាស់ប្តូរយល់ឃើញថា ថ្ងៃណាមួយ ការផ្លាស់ប្តូរត្រូវបានបង្ខំលើពួកគេដោយការវិវត្តហួសពីការគ្រប់គ្រងរបស់គេ។ បញ្ហានេះបានកើតឡើងក្នុងសេចក្តីរីកចម្រើនរបស់មនុស្ស។ ដោយបានសិក្សាពីសង្គមកម្ពុជា និង ប្រវត្តិសាស្ត្ររបស់ប្រទេសនេះដោយប្រុងប្រយ័ត្ន ហើយបានប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ខ្ញុំយល់ឃើញថាវាជាករណីយកិច្ចរបស់ខ្ញុំដោយបញ្ជាក់ថា ប្រសិនបើកំណែទម្រង់ពិតប្រាកដមិនបានធ្វើឡើងឆាប់ៗទេ ប្រទេសមានការប្រថុយប្រថាននៃការវិល

ត្រឡប់ទៅជាអំពើហិង្សា។ ខ្ញុំមានអារម្មណ៍ខកចិត្តយ៉ាងខ្លាំងចំពោះប្រជាពលរដ្ឋ ជាពិសេសយុវជន អ្នកក្រីក្រជនបទ និងអ្នកគ្មានសិទ្ធិ និង អ្នកដែលគេដកហូតទ្រព្យសម្បត្តិផ្សេងទៀត អំពីកង្វះនូវការរីកចម្រើនលើកំណែទម្រង់មួយចំនួនដែលបានសន្យា។ ប្រសិនបើកំណែទម្រង់ទាន់ពេល និង ពិតប្រាកដមិនបានធ្វើឡើងទេ ហើយបើភាគីម្ខាងធ្វើការដូចធម្មតាក្នុងរដ្ឋសភា ករណីនេះអាចមានហេតុផលកាន់តែច្រើនទៀត រួមមានទាំងការខកចិត្តចំពោះគោលការណ៍ជាមូលដ្ឋាននៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលផ្អែកលើតម្លៃនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

របាយការណ៍គ្រឹះ និងសំខាន់ចំនួនបួន ដែលខ្ញុំបានដាក់ជូនអង្គការសហប្រជាជាតិ ជុំវិញការងាររបស់ខ្ញុំក្នុងប្រទេសនេះក្នុងរយៈពេលប្រាំឆ្នាំកន្លងមក មានបំណងជួយដល់រដ្ឋាភិបាល គណបក្សប្រឆាំង និង ភាគីពាក់ព័ន្ធផ្សេង ទៀតក្នុងសង្គមកម្ពុជាដើម្បីទទួលការផ្លាស់ប្តូរ។ ខ្ញុំរីករាយចំពោះការរីកចម្រើនក្នុងការអនុវត្តអនុសាសន៍ខ្លះរបស់ខ្ញុំ ហើយការទទួលយកដាក់ចូលក្នុងរបៀបវារៈជាតិនូវអនុសាសន៍ដែលទាក់ទងនឹងកំណែទម្រង់ការបោះឆ្នោត និង សភាជាពិសេស។ ប៉ុន្តែ ខ្ញុំកត់សំគាល់ឃើញថា ចំណុចចុងក្រោយនេះមិនទាន់ឃើញការរីកចម្រើនជាក់លាក់ទេ ទោះបីវាជាគន្លឹះក្នុងការដោះស្រាយភាពជាប់គាំងនយោបាយបច្ចុប្បន្នក៏ដោយ។ នៅក្នុងចំណុចជួបគ្នានេះ អ្វីដែលត្រូវការនោះគឺជាការធានាដ៏ច្បាស់លាស់មួយដែលអនុសាសន៍សម្រាប់កំណែទម្រង់ការបោះឆ្នោត នឹងត្រូវអនុវត្តក្នុងកម្រឹតធ្ងន់ធ្ងរដែលតម្រូវដើម្បីទទួលបានការជឿជាក់ និង ការទុកចិត្តពីប្រជាពលរដ្ឋ ក្នុងពេលវេលាមួយយ៉ាងតឹងរ៉ឹងដើម្បីរៀបចំ និង អនុវត្តកំណែទម្រង់ រួមទាំងតាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។

ខ្ញុំបានចែករំលែកនូវទស្សនៈរបស់ខ្ញុំដោយស្មោះត្រង់ ជាមួយសមាជិកជាន់ខ្ពស់ខ្លះក្នុងជួររដ្ឋាភិបាល ក៏ដូចជាមេដឹកនាំបក្សប្រឆាំងដែលខ្ញុំបានបញ្ជាក់ពីតម្រូវការ និង ផលប្រយោជន៍របស់គេក្នុងការចូលក្នុងរដ្ឋសភា។ ខ្ញុំនឹងចាកចេញដោយសេចក្តីសង្ឃឹមថា សុភវិនិច្ឆ័យនឹងកើតមាននៅថ្ងៃណាមួយនៅក្នុងប្រទេសកម្ពុជា ហើយនឹងនាំប្រទេសនេះឆ្ពោះទៅរកសន្តិភាពយូរអង្វែង ការអភិវឌ្ឍស្មើភាពគ្នា លទ្ធិប្រជាធិបតេយ្យល្អប្រសើរ នីតិរដ្ឋពិតប្រាកដ និង មានការគោរពសិទ្ធិមនុស្សល្អប្រសើរជាងមុន។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា និង នៅហ្សឺណែវ ដែលបានជួយដល់ខ្ញុំក្នុងពេលបំពេញបេសកកម្មរបស់ខ្ញុំ។

**ចប់**

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកជាបុគ្គលឯករាជ្យ មិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំពេញការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់។ បច្ចុប្បន្ន លោកជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស និងជាមេធាវីអាជីពមួយរូប នៃគណៈមេធាវីខ្ទីលចឹមភីល នៅទីក្រុងឡុង។ លោកជាអនុប្រធានសង្គមអាស៊ាននៃនីតិអន្តរជាតិ និងជាអ្នកនិពន្ធសៀវភៅពាក់ព័ន្ធនឹងគម្រោងសំខាន់ៗ ទស្សនាវដ្ដីអាស៊ាននៃច្បាប់អន្តរជាតិ ដោយការិយាល័យព័ត៌មាននៃសាកលវិទ្យាល័យខេមប្រីដជ៍។*

*(*) ផែកមើលរបាយការណ៍ចុងក្រោយបំផុតរបស់អ្នករាយការណ៍ពិសេស បញ្ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប* (A/HRC/24/36)៖

http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session24/Pages/ListReports.aspx

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*

http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx

*រាល់សំណើព័ត៌មានទាក់ទងនឹងអ្នករាយការណ៍ពិសេស អាចសរសេរមកកាន់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា។ សូមទាក់ទងមក កញ្ញា ប៊ូស្រា រ៉ាម៉ាន់ តាមរយៈទូរស័ព្ទលេខ (+៨៥៥ ០១២ ៧៩០១៧៨/ អ៊ីម៉ែល៖ brahman@ohchr.org)*

សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប ៖

សូមមេត្តាទាក់ទងមក ឈ្មោះ សាបៀ ស៊ីលាយ៉ា សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉េល xcelaya@ohchr.org)

សម្រាប់ព័ត៌មានបន្ថែមអំពីការងាររបស់អ្នករាយការណ៍ ពិសេស សូមទាក់ទងមក ៖ នៅទីក្រុងហ្សឺណែវ កញ្ញា អ័លហ្គា ណាកាចូ តាមរយៈទូរ ស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉េល onakajo@ohchr.org

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើង លើបណ្ដាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights

**ទ្វីតធឺ៖** http://twitter.com/UNrightswire

**ហ្គោហ្គីល៖**Google+ gplus.to/unitednationshumanrights

**យូធូប៖** http://www.youtube.com/UNOHCHR

**បរិយាយសាច់រឿង ៖** http://storify.com/UNrightswire